| | |
|---|---|
| **គណៈកម្មការនិពន្ធ** | លោក ណុប វុណ |
| | លោក ប៉ែន ចំរើន |
| | លោក ម៉ម ចាន់សៀន |
| | កញ្ញា ហែម សង្វា |
| **គណៈកម្មការត្រួតពិនិត្យ** | លោក សិត សេង |
| | លោក ម៉ម ចាន់សៀន |
| | លោក ដោ៉ ប៉េងឡុង |
| **រៀបរៀង និងចងក្រង** | លោក ស្រី រតនៈ |

# អារម្ភកថា

លោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ជាទីមេត្រី កម្រងឯកសារដែលលោកគ្រូ-អ្នកគ្រូនិង ប្រិយ៍មិត្តអ្នកអាន កំពុងកាន់នៅនឹងដៃនេះ គឺជាឯកសារដែលចងក្រងបានពីវគ្គបំប៉នគ្រូឧទ្ទេសវិទ្យាសាស្ត្រនៃ សាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្ត ទាំង១៨នៅទូទាំងប្រទេស។ វគ្គបំប៉ននេះបានធ្វើនៅវិទ្យាស្ថានជាតិអប់រំ ពី **ថ្ងៃទី 05 កញ្ញា ដល់ថ្ងៃទី ១០ កញ្ញា ឆ្នាំ ២០១១** ក្រោមកិច្ចសហប្រតិបត្តិការរបស់ក្រសួងអប់រំយុវជន និងកីឡា និងគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ (STEPSAM2) ក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូឧទ្ទេសបន្ថែមទៀតលើផ្នែកវិទ្យាសាស្ត្របង្រៀន និងរៀនដោយផ្អែកលើការរិះរក, ការសិក្សាស្រាវជ្រាវមេរៀន និងជំនាញក្នុងការសង្កេតថ្នាក់ ។

ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់លោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្ត អ្នកអានទាំងអស់ ក្រុមការងារយើងខ្ញុំបានប្រមូលនូវរាល់ឯកសារទាំងអស់ដែលបានប្រើក្នុងវគ្គបំប៉នសម្រាប់គ្រូ សាលាគរុកោសល្យទាំងអស់មកចងក្រងជាសៀវភៅនេះឡើង។ កម្រងឯកសារនៅក្នុងសៀវភៅនេះ គឺ ជាទន់សម្រាប់ជួយលោកគ្រូ -អ្នកគ្រូអោយអាចកែលម្អការបង្រៀនរបស់ខ្លួនឆ្ពោះទៅរកការបង្រៀន និងរៀនផ្អែកលើការរិះរក ដែលផ្តោតទៅលើការគិតរបស់សិស្សជាចម្បង។ នៅក្នុងកម្រងឯកសារនេះដែរ មានបង្ហាញពីរបៀបរៀបចំឯកសារមួយចំនួន ដើម្បីឱ្យការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូមានសកម្មភាពល្អ ដូចជា កិច្ចតែងការបង្រៀន សន្លឹកកិច្ចការ ប្លង់ក្តារខៀន និងកំណត់សម្គាល់មេរៀនជាដើម។

ក្រុមការងារយើងខ្ញុំសូមអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតមានដោយយថាហេតុទាំងខ្លឹមសារ និងបច្ចេកទេសក្នុងការចងក្រងឯកសារនេះ។

ក្រុមការងារយើងខ្ញុំរងចាំទទួលការរិះគន់កែលម្អពីសំណាក់លោកគ្រូ-អ្នកគ្រូ និងប្រិយ៍មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើឱ្យកម្រងឯកសារនេះកាន់តែមានសារប្រយោជន៍ដល់ការលើកកម្ពស់ការបង្រៀន និងរៀនថែមទៀត។

**គ្រូឧទ្ទេសថ្នាក់ជាតិ**
**និង**
**ក្រុមការងារគម្រោងអប់រំគ្រូវិទ្យាសាស្ត្រ** (STEPSAM2)

# មាតិកា

គណៈកម្មការនិពន្ធ ............ i

អារម្ភកថា ............ ii

មាតិកា ............ iii

១. កិច្ចតែងការបង្រៀនគម្រូរបស់គ្រូឧទ្ទេសថ្នាក់ជាតិ

១.១. អគ្គីសនី ............ 3

១.២. កម្ដៅ និងរូបធាតុ ............ 8

១.៣. លក្ខណៈរបស់ផ្កា ............ 14

១.៤. ប្រភេទដីខុសៗគ្នា(ស្រទាប់ដីលើ និងស្រទាប់ក្រោម) ............ 20

២. កិច្ចតែងការបង្រៀនគម្រូរបស់សិក្ខាកាម

២.១. រូបធាតុ ............ 25

២.២. រូបធាតុ(ការចម្លង និងការរីកមាឌនៃអង្គធាតុរឹង) ............ 31

២.៣. ប្រព័ន្ធព្រះអាទិត្យ ............ 36

២.៤. វិញ្ញាណប្រាំរបស់ខ្ញុំ ............ 41

៣. ផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅក្នុងសាលាគរុកោសល្យ និងវិក្រឹតការ រាជធានី–ខេត្ត

៣.១. ខេត្តតាកែវ ............ 49

៣.២. ខេត្តព្រៃវែង ............ 52

៣.៣. រាជធានី ភ្នំពេញ ............ 55

៣.៤. ខេត្តកណ្ដាល ............ 58

៣.៥. ខេត្តស្ទឹងត្រែង ............ 61

៣.៦. ខេត្តបន្ទាយមានជ័យ ............ 64

៣.៧. ខេត្តកំពង់ឆ្នាំង ............ 67

៣.៨. ខេត្តកំពង់ស្ពឺ ............ 70

៣.៩. ខេត្តពោធិសាត់ ............ 73

៣.១០. ខេត្តស្វាយរៀង ........ 76

៣.១១. ខេត្តក្រចេះ ........ 79

៣.១២. ខេត្តសៀមរាប ........ 82

៣.១៣. ខេត្តព្រះវិហារ ........ 85

៣.១៤. ខេត្តកំពត ........ 88

៣.១៥. ខេត្តព្រះសីហនុ ........ 91

៣.១៦. ខេត្តបាត់ដំបង ........ 94

៣.១៧. ខេត្តកំពង់ចាម ........ 97

៣.១៨. ខេត្តកំពង់ធំ ........ 100

## ១. កិច្ចតែងការបង្រៀនគម្រូ របស់គ្រូឧត្តមសថ្នាក់ជាតិ

### ១.១. អគ្គីសនី

### ១.២. កម្ដៅ និងរូបធាតុ

### ១.៣. លក្ខណៈរបស់ផ្កា

### ១.៤. ប្រភេទដីខុសៗគ្នា (ស្រទាប់ដីលើ និងស្រទាប់ក្រោម)

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី៥

២. មេរៀន: អគ្គីសនី

៣. រយពេល: ១ម៉ោង

៤. វត្ថុបំណង:

. សិស្សបង្កើតថ្មពិលពីវត្ថុផ្សេងៗ

. សិស្សមានជំនាញក្នុងការធ្វើពិសោធ

. សិស្សមានចំណង់ចំណូលចិត្តក្នុងការស្រាវជ្រាវ និងរៀនវិទ្យាសាស្ត្រ

៥. ដំណើរការបង្រៀន

| សកម្មភាពសិស្ស | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យអនាម័យ<br>. សណ្តាប់ធ្នាប់<br>. អវត្តមាន | ជំហានទី១ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| . គ្រូបង្ហាញឌីណាម៉ូកង់ ដោយបង្ហាញឱ្យអំពូលភ្លឺ។<br>. ថ្មពិល អាគុយ<br>. បង្ហាញអំពូលភ្លើង ឧបករណ៍បង្ហាញសម្លេង និងវ៉ុលម៉ែត្រ។<br>. តើអំពូលភ្លើងភ្លឺ ឧបករណ៍បញ្ចេញសម្លេងលឺ វ៉ុលម៉ែត្រមានលំងាកដោយសារអ្វី? | ជំហានទី២<br><br><br>ថ្មពិល<br><br>ឧបករណ៍បញ្ចេញសម្លេង<br><br>អំពូល<br><br>វ៉ុលម៉ែត្រ | . សិស្សឆ្លើយ<br>. អំពូលភ្លឺ ឧបករណ៍សម្លេងលឺ វ៉ុលម៉ែត្រមានលំងាក ដោយសារចាប់ជាមួយថ្មពិលអាគុយ និងឌីណាម៉ូ<br>. សិស្សសង្កេត |

. បង្ហាញថ្មពិលថ្មី ថ្មពិលដែលបកសំបកក្រៅចេញ និងថ្មពិលដែលយកផ្នែកខាងក្នុងចេញ ដោយចាប់ជាមួយអំពូលភ្លើង ឬឧបករណ៍បញ្ចេញសម្លេង មកបង្ហាញសិស្ស។ ពេលចាប់ជាមួយសំបកថ្មពិល




. សិស្សឆ្លើយ

គ្រូសួរសិស្ស
តើយើងធ្វើយ៉ាងដូចម្តេចដើម្បីបង្កើតបានជាថ្មពិល?
. គ្រូបង្ហាញថ្មពិល ដែលធ្វើអំពីផ្លែក្រូចដោយចាប់ជាមួយឧបករណ៍បញ្ចេញសម្លេង។

. សួរសិស្ស
ចុះបើអង្គធាតុផ្សេង តើវាអាចបង្កើតបានជាថ្មពិលដែរ ឬទេ?




. សិស្សសង្កេត

១.សំណួរ៖ តើវត្ថុរាវណាដែលអាចបង្កើតបានជាថ្មពិល?

២. ការទស្សទាយ
. ឱ្យសិស្សពិភាក្សា និងបំពេញនៅលើសន្លឹកកិច្ចការ
. ឱ្យសិស្សតំណាងក្រុមឡើងបង្ហាញពីការទស្សន៍ទាយរបស់ពួកគេនៅលើក្តារខៀន។

ចែកសន្លឹកកិច្ចការ

| អង្គធាតុរាវ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ទឹកក្រូចឆ្មា | | | | | |
| ទឹកក្រូចកំប៉ុង | | | | | |
| ទឹកអំបិល | | | | | |
| ទឹកខ្មេះ | | | | | |
| ទឹកម៉ាស៊ីន | | | | | |
| ទឹកត្រី | | | | | |
| ទឹកស៊ីអ៊ីវ | | | | | |
| ល្បាយនៃវត្ថុរាវ | | | | | |
| ទឹកថ្នាំលាងរបួស | | | | | |
| ទឹកថ្នាំលាងរបួស និងទឹកអំបិល | | | | | |

. សិស្សពិភាក្សាតាមក្រុម និងបំពេញលើសន្លឹកកិច្ចការ។
. សិស្សតំណាងក្រុមឡើងបង្ហាញ

៣. ពិសោធន៍

. ឱ្យសិស្សធ្វើពិសោធតាមក្រុម

. ពិនិត្យសកម្មភាពពិសោធសិស្ស




. សិស្សធ្វើពិសោធតាមក្រុម និងកត់ត្រាលទ្ធផលក្នុងសន្លឹកកិច្ចការ

៤. លទ្ធផល

. ឱ្យសិស្សតំណាងក្រុមឡើងបង្ហាញលទ្ធផលរបស់ក្រុមខ្លួន

តារាងលទ្ធផល

| អង្គធាតុរាវ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ទឹកក្រូចឆ្មា | | | | | |
| ទឹកក្រូចកំប៉ុង | | | | | |
| ទឹកអំបិល | | | | | |
| ទឹកខ្មេះ | | | | | |
| ទឹកម៉ាស៊ីន | | | | | |
| ទឹកត្រី | | | | | |
| ទឹកស៊ីអ៊ីវ | | | | | |
| ល្បាយនៃវត្ថុរាវ | | | | | |
| ទឹកថ្នាំលាងរបួស | | | | | |
| ទឹកថ្នាំលាងរបួស និងទឹកអំបិល | | | | | |

. សិស្សតំណាងក្រុមឡើងបង្ហាញលទ្ធផលនៅលើក្តារខៀន។

៥. វិភាគ និងសន្និដ្ឋាន

. គ្រូសំយោគលើលទ្ធផលរបស់សិស្ស

. គ្រូអាចយកថ្មពិលដែលសិស្សធ្វើបាន មកតជាសេរី រួចចាប់ជាមួយអំពូល

វត្ថុរាវដែលអាចធ្វើបានជាថ្មពិលមាន:

. ទឹកក្រូចឆ្មា

. ទឹកក្រូចកំប៉ុង

. ទឹកថ្នាំលាងរបួស លាយជាមួយទឹកអំបិល

. ទឹកខ្មេះ

. ទឹកស៊ីអ៊ីវ

. ល្បាយ

. សិស្សកត់ត្រា ការសន្និដ្ឋាន ចូលក្នុងសន្លឹកកិច្ចការ

| | | |
|---|---|---|
| . គ្រូពិសោធបង្ហាញដល់សិស្សអំពីថ្មពិលដែលបង្កពីសន្លឹកអាលុយមីញ៉ូម ធ្យូង និងល្បាយដែលមានថ្នាំលាងរបួស និងទឹកអំបិលដោយចាប់ជាមួយឧបករណ៍បញ្ចេញសម្លេង ឬអំពូល។<br><br>. គ្រូបង្ហាញផ្លែស្វាយសម្រាប់ធ្វើថ្មពិល។ | <u>ជំហានទី៤</u><br><br> | . សិស្សសង្កេត |
| . គ្រូឱ្យសិស្សសាកល្បងធ្វើថ្មពិលពីវត្ថុផ្សេងៗ ដែលមាននៅជុំវិញផ្ទះរបស់ពួកគេ ហើយយកមកបង្ហាញនៅម៉ោងក្រោយ។ | <u>ជំហានទី៥</u><br>សាកល្បងនៅផ្ទះ | . សាកល្បងនៅផ្ទះរួចយកមកបង្ហាញគ្រូនៅម៉ោងក្រោយ។ |

# សន្លឹកកិច្ចការ

អាគុយ និងថ្មពិលបង្កឡើងពីធាតុពីរត្រាំក្នុងអាស៊ីត ឬល្បាយនៃអង្គធាតុជាច្រើន។ វាអាចបង្កើតបានជាថាមពលអគ្គីសនី។

សំណួរ៖ តើអង្គធាតុណាខ្លះដែលអាចបង្កើតបានជាថ្មពិល?

១. ចូរប្អូនធ្វើការទស្សទាយ

| អង្គធាតុរាវ | |
|---|---|
| ទឹកក្រូចឆ្មា | |
| ទឹកក្រូចកំប៉ុង | |
| ទឹកអំបិល | |
| ទឹកខ្មេះ | |
| ទឹកម៉ាស៊ីន | |
| ទឹកត្រី | |
| ទឹកស៊ីអ៊ីវ | |
| ល្បាយនៃវត្ថុរាវ | |
| ទឹកថ្នាំលាងរបួស | |
| ទឹកថ្នាំលាងរបួស និងទឹកអំបិល | |

២. ពិសោធន៍ ចូរគូររូបពីការធ្វើថ្មពិលរបស់អ្នកក្នុងផ្នែកខាងស្តាំ




៣. លទ្ធផល

| អង្គធាតុរាវ | |
|---|---|
| ទឹកក្រូចឆ្មា | |
| ទឹកក្រូចកំប៉ុង | |
| ទឹកអំបិល | |
| ទឹកខ្មេះ | |
| ទឹកម៉ាស៊ីន | |
| ទឹកត្រី | |
| ទឹកស៊ីអ៊ីវ | |
| ល្បាយនៃវត្ថុរាវ | |
| ទឹកថ្នាំលាងរបួស | |
| ទឹកថ្នាំលាងរបួស និងទឹកអំបិល | |

៤. វិភាគ និងសន្និដ្ឋាន

អង្គធាតុជាច្រើនដែលអាចបង្កើតបានជាថ្មពិលមាន....................

..........................................................................................................។

ប៉ុន្តែមានអង្គធាតុខ្លះធ្វើឱ្យឧបករណ៍បញ្ចេញសម្លេងលឺ និងអង្គធាតុខ្លះទៀតលឺ..........................................។

ចូរប្អូនសាកល្បងធ្វើថ្មពិលពីវត្ថុផ្សេងៗដែលមាននៅជុំវិញផ្ទះរបស់ប្អូន។

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី៥

២. មេរៀន: កម្ដៅ និងរូបធាតុ

៣. រយៈពេល: ៥០នាទី

៤. វត្ថុបំណង:

. ពណ៌នាបានថាពណ៌ខុសគ្នាស្រូបកម្ដៅព្រះអាទិត្យខុសគ្នាតាមរយៈសំណួរបំផុសរបស់គ្រូ

. ធ្វើពិសោធបង្ហាញថាពណ៌ស្រូបកម្ដៅព្រះអាទិត្យបានខ្លាំងជាងគេបំផុត

. ជ្រើសរើសពណ៌ខោអាវត្រឹមត្រូវអាស្រ័យទៅនឹងស្ថានភាព ជាពិសេសនៅក្រោមកម្ដៅថ្ងៃ។

៥. សម្ភារ:

. ដបទឹកសុទ្ធ បំពង់បឺត លក្ខណ៍ ទឹក ថ្នាំកំប៉ុងពណ៌ស និងខ្មៅ កាំបិត

៦. ដំណើរការបង្រៀន

| សកម្មភាពសិស្ស | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូពិនិត្យអវត្តមានសិស្សគ្រូចែកសិស្សអង្គុយជាក្រុម | <u>ជំហានទី១</u><br>គ្រូតពិនិត្យថ្នាក់(២នាទី) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| . ហេតុអ្វីបានជាចុតស្លាបព្រាឡើងក្ដៅនៅពេលដែលចុងស្លាបព្រាម្ខាងទៀត ត្រូវបានដុតកម្ដៅ?<br><br>.តើមានអ្វីកើតឡើងចំពោះមាឌរបស់អង្គធាតុរឹង អង្គធាតុរាវ និងឧស្ម័ន នៅពេលឡើងក្ដៅ? | <u>ជំហានទី២</u><br>រំលឹកមេរៀនចាស់(៥នាទី)<br>លោហ:ឆ្លងកម្ដៅបានល្អ<br><br>កម្ដៅធ្វើឱ្យអង្គធាតុរឹង និងឧស្ម័នរីកមាឌ។ | . ដោយសារស្លាបព្រាលោហ:ចម្លងកម្ដៅពីចុងម្ខាងទៅចុងម្ខាងទៀត<br><br>. រីកមាឌ |

| | | |
|---|---|---|
| . គ្រូបង្ហាញដបទឹកសុទ្ធទទេហើយសួរ: តើមានអ្វីនៅក្នុងដប?<br>. គ្រូធ្វើពិសោធន៍បង្ហាញ:<br>ដបទឹកសុទ្ធទទេត្រូវបានគ្របដោយទុយោ។<br>តើមានអ្វីកើតឡើងចំពោះខ្យល់នៅក្នុងដបប្រសិនបើ ដបនោះឡើងក្តៅ?<br>ប្រសិនបើដបនោះឡើងក្តៅ តើធ្វើដូចម្តេចដើម្បីដឹងថាខ្យល់រីកមាឌ? | <u>ជំហានទី៣</u><br>កម្តៅ និងរូបធាតុ (៣០នាទី) | . ខ្យល់<br><br>. ខ្យល់រីកមាឌ<br>. ដាក់ប៉េងប៉ោងនៅលើមាត់ដប ហើយធ្វើឱ្យដបឡើងក្តៅ ពេលនោះឃើញប៉េងប៉ោងរីកធំពេលខ្យល់រីកមាឌ។ |
| ចុះបើដាក់ទុយោនៅក្នុងទឹកតើមានអ្វីកើតឡើង?<br>គ្រូដាក់ទុយោនៅក្នុងទឹក តើមានអ្វីកើតឡើង? | ដបទទេឡើងក្តៅធ្វើខ្យល់នៅក្នុងដបឡើងក្តៅ។ ខ្យល់រីកមាឌ និងធ្វើឱ្យមានពពុះទឹកកើតឡើងនៅក្នុងកែវទឹកពេលបំពង់ជ័រត្រូវបានដាក់នៅក្នុងកែវទឹក។ | |
| គ្រូដាក់ទុយោនៅក្នុងកែងទឹក ដែលមានលក្ខណ៍ និងដាក់ដបទឹកសុទ្ធចូលក្នុងកែវទឹកក្តៅ។<br><br>ឱ្យសិស្សសង្កេត! | ១.   | . សិស្សសង្កេតឃើញពពុះទឹកនៅក្នុងកែវទឹក |
| បន្ទាប់មកគ្រូយកដបទឹកសុទ្ធដាក់ក្នុងកែវទឹកត្រជាក់។<br><br>ឱ្យសិស្សសង្កេត! | ២.   | . សិស្សសង្កេតឃើញទឹកហូរពីកែវទឹកត្រជាក់ចូលក្នុងដបវិញ។ |

<table>
<tr>
<td>. តើមានអ្វីកើតឡើង ប្រសិនបើដបទទេត្រូវបានផ្កាប់ដាក់ក្នុងដបទឹកដូចបង្ហាញក្នុងរូប?<br>. ចុះបើដាក់នៅក្រោមកម្តៅថ្ងៃ តើមានអ្វីកើតឡើង ចំពោះឧបករណ៍នេះ? ហេតុអ្វី?<br>. ឥឡូវខ្ញុំដាក់ដបពណ៌ខុសគ្នាផ្កាប់នៅក្នុងដបទឹកសុទ្ធ នៅក្រោមកម្តៅថ្ងៃ។</td>
<td><br>ដោយសារតែពន្លឺព្រះអាទិត្យ ខ្យល់នៅក្នុងដបឡើងក្តៅ និងរីកមាឌធ្វើឱ្យមានពពុះនៅក្នុងទឹក។</td>
<td>. គ្មានអ្វីកើតឡើង<br><br>. សិស្សអាចឆ្លើយថាមានពពុះចេញពីបំពង់បឺត។</td>
</tr>
<tr>
<td colspan="3">តើពណ៌មានឥទ្ធិពលទៅលើការស្រូបកម្តៅព្រះអាទិត្យ ឬទេ?<br>ប្រសិនបើមាន តើពណ៌អ្វីដែលស្រូបកម្តៅព្រះអាទិត្យបានខ្លាំងជាងគេ?</td>
</tr>
<tr>
<td>. គ្រូឱ្យសិស្សពិភាក្សាតាមក្រុម គ្រូឱ្យសិស្សបង្កើតសម្មតិកម្ម។ ឱ្យសិស្សពន្យល់ចម្លើយនៅក្នុងសម្មតិកម្ម។</td>
<td>សម្មតិកម្មៈ<br><br>ដបខ្មៅ ដបស ដបថ្លា<br><br><u>ពិសោធន៍</u><br>. រៀបចំដបបី ខ្មៅ ស និងថ្លា ដែលមានគ្របជាមួយបំពង់បឺត។<br>. ចាក់ទឹកចូលក្នុងដបទឹកដែលកាត់មាត់ដបចេញ។<br>. ផ្កាប់ដបទាំងបី ពីលើកំណាត់ដបទឹក<br>. ដាក់ដបទាំងបីហាលថ្ងៃ</td>
<td>. សិស្សអាចឆ្លើយ ចាស/ បាទ ឬទេ។<br><br>. សិស្សរៀបចំពិសោធន៍ និងកត់ត្រាលទ្ធផលចូលក្នុងតារាងលទ្ធផល។</td>
</tr>
</table>

<table>
<tr>
<td>គ្រូឱ្យសិស្សសន្និដ្ឋានតាមរយៈលទ្ធផល។</td>
<td>. សង្កេត និងរាប់ចំនួនពពុះទឹករយៈពេល ៣នាទី<br>. កត់ត្រាចូលក្នុងតារាងលទ្ធផល<br>. យកដៃស្ទាបដប តើមួយណាក្តៅជាង?<br><u>លទ្ធផល</u> រយៈពេល៣នាទី<br><table><tr><td>ដប</td><td>ចំនួនពពុះទឹក</td><td>កំណត់សម្គាល់</td></tr><tr><td>ខ្មៅ</td><td></td><td></td></tr><tr><td>ស</td><td></td><td></td></tr><tr><td>ផ្កា</td><td></td><td></td></tr></table><br><u>សន្និដ្ឋាន</u><br>. ពពុះចេញពីដបពណ៌ខ្មៅច្រើនជាងពពុះចេញពីដបផ្កា និងពណ៌ស<br>. ដូចនេះយើងអាចសន្និដ្ឋានថា ពណ៌មានឥទ្ធិពលទៅលើការស្រូបកម្តៅថ្ងៃបានលឿនជាងពណ៌ស្រាល ឬផ្កា</td>
<td><u>សិស្សសន្និដ្ឋាន</u><br>. ពណ៌ខ្មៅស្រូបធ្វើឱ្យមានពពុះទឹកច្រើន។ ដូចនេះពណ៌ខ្មៅស្រូបកម្តៅថ្ងៃបានល្អជាងពណ៌ស ឬពណ៌ផ្កា។</td>
</tr>
<tr>
<td>តើដបពណ៌ខ្មៅ និងដបស្រោបដោយសន្លឹកអាលុយមីញ៉ូម មួយណាស្រូបកម្តៅខ្លាំងជាង? ហេតុអ្វី?<br>. ប្រសិនបើមានអាវពណ៌ខ្មៅ និងពណ៌ស តើអ្នកជ្រើសរើសអាវពណ៌ណាពេលអ្នកត្រូវធ្វើការក្រោមកម្តៅថ្ងៃ?</td>
<td><u>ជំហានទី៤</u><br>ពង្រឹងចំណេះដឹង (១០នាទី)<br><br></td>
<td>ដបពណ៌ខ្មៅស្រូបកម្តៅថ្ងៃបានល្អជាងដបស្រោបសន្លឹកអាលុយមីញ៉ូម។<br>អាវពណ៌ស ព្រោះវាមិនស្រូបកម្តៅព្រះអាទិត្យខ្លាំងឡើយ បើធៀបនិងពណ៌ខ្មៅ។</td>
</tr>
<tr>
<td>សូមអានមេរៀនបន្ថែមទៀតពេលនៅផ្ទះ។</td>
<td><u>ជំហានទី៥</u><br>បណ្តាំផ្ញើ</td>
<td>. សិស្សស្តាប់ដំបូន្មានគ្រូ និងជំរាបលាទៅផ្ទះ។</td>
</tr>
</table>

# សន្លឹកកិច្ចការ

## កម្ដៅ

<u>សំណួរគន្លឹះ</u>

តើពណ៌មានឥទ្ធិពលទៅលើការស្រូបកម្ដៅព្រះអាទិត្យ ឬទេ?
ប្រសិនបើមាន តើពណ៌អ្វីដែលស្រូបកម្ដៅព្រះអាទិត្យបានខ្លាំងជាងគេ?

<u>សម្មតិកម្ម</u>

<u>ពិសោធន៍</u>




. រៀបចំដបបី ខ្មៅ ស និង ដបថ្លា ដែលមានគ្របជាមួយបំពង់បឺត។

. ចាក់ទឹកចូលក្នុងដបទឹកដែលកាត់មាត់ដបចេញ។

. ផ្កាប់ដបដែលគ្របដោយគម្របមានទុយោទាំងបីលើកំណាត់ដបទឹក។

. ដាក់ដបទាំងបីហាលថ្ងៃ

. សង្កេត នឹងរាប់ចំនួនពពុះទឹក ក្នុងរយៈពេល ៣នាទីម្ដង រួចហើយកត់ត្រាចូលក្នុងតារាងលទ្ធផល

. យកដៃស្ទាបដប តើមួយណាក្ដៅជាង?

<u>លទ្ធផល</u>

ចូរកត់ត្រាចំនួនពពុះទឹកក្នុងរយៈ ៣នាទីម្តង។ សូមសរសេរចូល នូវកំណត់សម្គាល់ផ្សេងៗ នៅក្នុងតារាង «កំណត់សម្គាល់ផ្សេងៗ»។

| ដប | ចំនួនពពុះទឹក | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|
| ពណ៌ខ្មៅ | | |
| ពណ៌ស | | |
| ដបថ្លា | | |

<u>សន្និដ្ឋាន</u>

តើពណ៌មានឥទ្ធិពលទៅលើការស្រូបកម្តៅថ្ងៃ ឬទេ? តើមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចរវាងចំនួនពពុះទឹក និងអត្រាស្រូបកម្តៅថ្ងៃ?

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី៤

២. មេរៀន: លក្ខណៈរបស់ផ្កា (ជំពូកទី១)

៣. រយៈពេល: ៥០នាទី

៤. វត្ថុបំណង:

- ចំណេះដឹង
  - កំណត់ពីផ្នែកផ្សេងៗរបស់ផ្កាបានត្រឹមត្រូវតាមរយៈការសង្កេតផ្កាដោយផ្ទាល់។
  - កំណត់ពីផ្ការបស់រុក្ខជាតិម្ទ៉ូល្វាកូទីលេដូន និងឌីកូទីលេដូនបានត្រឹមត្រូវតាមរយៈការសង្កេត និងប្រៀបធៀបផ្កាដោយផ្ទាល់។
- ជំនាញ
  - ធ្វើចំណាត់ថ្នាក់រុក្ខជាតិម្ទ៉ូល្វាកូទីលេដូន និងឌីកូទីលេដូនបានត្រឹមត្រូវតាមរយៈការសង្កេតផ្ការបស់វា។
- ឥរិយាបថ
  - ស្រលាញ់ និងថែរក្សាផ្ការបស់រុក្ខជាតិ។

៥. សម្ភារៈ

ផ្ការុក្ខជាតិម្ទូល្វាកូទីលេដូន និងឌីកូទីលេដូន ស្កុត កន្ត្រៃ ក្រដាស A4។

៦. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យថ្នាក់ និងមតិស្វាគម<br>. គ្រូតពិនិត្យអវត្តមាន | <u>ជំហានទី១</u><br>លំនឹងថ្នាក់ (២នាទី)<br>. ស្វាគម និងពិនិត្យអវត្តមាន | . ស្តាប់ និងស្វាគម<br>. ប្រធានថ្នាក់រាយការណ៍ |
| . កាលពីសប្តាហ៍មុនយើងបានរៀនរួចមកហើយអំពីលក្ខណៈរបស់រុក្ខជាតិ។ | <u>ជំហានទី២</u><br>រំលឹកមេរៀនចាស់ (៦នាទី)<br><u>លក្ខណៈរុក្ខជាតិ</u> | . ឡើងរៀបរាប់ពីលក្ខណៈរបស់រុក្ខជាតិ។ |

| | | |
|---|---|---|
| . បង្ហាញរុក្ខជាតិ (ម៉ូណូកូទីលេដូន) ហើយឱ្យសិស្សម្នាក់ទៀតឡើងបកស្រាយ។ | <br>រុក្ខជាតិម៉ូណូកូទីលេដូន | . រុក្ខជាតិនេះមានស្លឹក ដើម ឫស...<br>. រុក្ខជាតិនេះ ស្លឹកមានទ្រនុងបែកខ្នែង ដើមបែកមែកសាខា មានឫសកែវ។ |
| . បង្ហាញរុក្ខជាតិ (ឌីកូទីលេដូន) ហើយឱ្យសិស្សម្នាក់ទៀតឡើងបកស្រាយ។<br>. ឱ្យសិស្សបង្ហាញពីលក្ខណៈខុសគ្នារបស់រុក្ខជាតិទាំងពីរ | . រុក្ខជាតិម៉ូណូកូទីលេដូនៈ ស្លឹកមានទ្រនុងស្រប ដើមទោល និងមានឫសស្វែង។<br><br>រុក្ខជាតិឌីកូទីលេដូន | . រុក្ខជាតិមួយនេះស្លឹកមានទ្រនុងស្រប គ្មានឫសកែវ វាជារុក្ខជាតិម៉ូណូកូទីលេដូន ចំណែករុក្ខជាតិមួយនេះ ស្លឹកមានទ្រនុងបែកខ្នែង ដើមបែកមែក មានឫសកែវវាជារុក្ខជាតិឌីកូទីលេដូន។ |
| . ក្រៅពីស្លឹក ដើម និងឫស តើរុក្ខជាតិមានសរីរាង្គសំខាន់អ្វីទៀត? | . រុក្ខជាតិឌីកូទីលេដូនៈ ស្លឹកមានទ្រនុងបែកខ្នែង ដើមបែកមែកសាខា និងមានឫសកែវ។<br>. គ្រប់រុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនសុទ្ធតែមានផ្កា។ | . ផ្កា |

| | | |
|---|---|---|
| . តើអ្នកមានចម្ងល់អំពីផ្កាដែរឬទេ? សូមលើកជាសំណួរ។<br>. ប្តូរសរុបចម្លើយសិស្ស ហើយលើកជាសំណួរគន្លឹះ | <u>ជំហានទី៣</u><br><u>មេរៀនប្រចាំថ្ងៃ</u> ( ៣៥នាទី)<br>៣. វដ្តជីវិតរបស់រុក្ខជាតិ<br>៣. លក្ខណៈរបស់ផ្កា<br><u>សំណួរគន្លឹះ</u><br>**តើផ្កាមានផ្នែកអ្វីខ្លះ?** | . សួរសំណួរតាមគេចង់ដឹងដូចជា:<br>តើផ្កាមានក្លិនអ្វី? |
| . ឱ្យសិស្សគិតហើយឡើងគូររូបរបស់ផ្កា ដោយដាក់ឈ្មោះផ្នែកផ្សេងៗរបស់វា។ | **សម្មតិកម្ម**<br> | . គូររូបផ្កាតាមដែលគេធ្លាប់ឃើញ ហើយ |
| . ឱ្យសិស្សធ្វើការជាក្រុម (១ក្រុមគ្នា៤នាក់)<br>. ឱ្យសិស្សគិត និងពន្យល់ពីដំណើរការសង្កេតបន្តិច រួចហើយពន្យល់គាត់ពីដំណើរការ និងសកម្មភាពដែលត្រូវធ្វើ។<br>. ចែកសន្លឹកកិច្ចការ ផ្កា និងសម្ភារផ្សេងៗទៀត។<br>. ឱ្យសិស្សមួយក្រុមយកលទ្ធផលរបស់ខ្លួនទៅបិទនៅក្តារខៀន ហើយដាក់ឈ្មោះផ្កា (បើសិស្សមិនចេះ គ្រូបង្ហាញពីរូបភាពផ្កាដែលមានដាក់ឈ្មោះផ្នែករបស់ផ្កា)។<br>. ឱ្យសិស្សគូររូបតំណាងដែលស្រដៀង និងផ្ការបស់គាត់។សិស្សក្នុងក្រុមផ្សេងទៀត គូររូបតំណាងលើសន្លឹកកិច្ចការ<br>. ពន្យល់ និងនាំសិស្សឱ្យជ្រាក្រាមផ្កា។ | (ដំណើរការសង្កេតដូចមានរៀបរាប់នៅក្នុងសន្លឹកកិច្ចការ)<br><u>លទ្ធផល</u><br><br> | . ចូលតាមក្រុម<br>. សង្កេតផ្កាដោយផ្ទាល់នៅខាងក្រៅ យកផ្កាមកហែកមើលជាដើម។<br>. សិស្សទទួលសន្លឹកកិច្ចការមួយម្នាក់ និងមានផ្កា៤ប្រភេទ។<br>. យកមកបិតនៅក្តារខៀន ហើយពន្យល់ពីផ្នែកផ្សេងៗរបស់ផ្កា ដូចជាត្របក ស្រទាប់ កេសរឈ្មោល កេសរញី...។<br>. គូររូបតំណាងផ្កាដែលគេសង្កេត។<br>. គូរជ្រាក្រាមផ្កាតាមគ្រូពន្យល់។<br>. សិស្សសរសេរសន្និដ្ឋាន នៅលើសន្លឹកកិច្ចការ |

| | | |
|---|---|---|
| . ឱ្យសិស្សសរសេរសន្និដ្ឋាន នៅលើសន្លឹកកិច្ចការរបស់ខ្លួន។<br>. ឱ្យសិស្សម្នាក់សរសេរសន្និដ្ឋាននៅលើក្ដារខៀន។<br>. កែលំអរចំលើយសិស្ស។ | <u>សន្និដ្ឋាន</u><br>ផ្កាទាំងអស់សុទ្ធតែមានត្របក ស្រទាប់កេសរឈ្មោល និងកេសរញី។ ផ្កាដែលមានត្របក និងស្រទាប់មានចំនួន៣ ឬពហុគុណ៣ ជាផ្ការបស់រុក្ខជាតិម៉ូណូកូទីលេដូន ហើយផ្កាដែលមានត្របក និងស្រទាប់មានចំនួន៤-៥ ជាផ្ការបស់រុក្ខជាតិឌីកូទីលេដូន។ | . សិស្សម្នាក់សរសេរសន្និដ្ឋាននៅលើក្ដារខៀន<br>. កែលម្អចម្លើយរបស់ខ្លួន |
| . តើយើងអាចធ្វើចំណាត់ថ្នាក់រុក្ខជាតិ ដោយពិនិត្យ ទៅលើលក្ខណៈអ្វីខ្លះ?<br>. ឱ្យសិស្សនិយាយជាមួយមិត្តភ័ក្តិរបស់គេ ប្រាប់គ្នាទៅវិញទៅមក អំពីអ្វី ដែលគេបានរៀនក្នុងមួយម៉ោងសិក្សានេះ។<br>. ហៅសិស្សម្នាក់ ឬពីរនាក់ឱ្យរាយការណ៍ពីអ្វីដែលមិត្តភ័ក្តិរបស់គេបានប្រាប់។ | <u>ជំហានទី៤</u><br>ពង្រឹងពុទ្ធិ (៥-៦នាទី)<br>. រុក្ខជាតិត្រូវបានធ្វើចំណាត់ថ្នាក់ ដោយពិនិត្យមើល ស្លឹក ដើម ឫស និងផ្ការបស់វា។<br>. ផ្នែកផ្សេងៗរបស់ផ្កា ត្របក ស្រទាប់ កេសរញី កេសរ ឈ្មោល ...។ល។ | . ដោយពិនិត្យ ស្លឹក ដើម ឫស និងផ្ការបស់វា។<br><br>. សិស្សនិយាយជាមួយគ្នា ជាដៃគូអំពីអ្វីដែលគេបានរៀនថ្ងៃនេះ។<br><br>. រាយការណ៍ដោយផ្អែកលើចំលើយរបស់មិត្តភ័ក្តិ។ |
| . តើយើងអាចធ្វើចំណាត់ថ្នាក់រុក្ខជាតិដោយពិនិត្យទៅលើលក្ខណៈអ្វីផ្សេងទៀត? | <u>ជំហានទី៥</u><br>បណ្តាំផ្ញើ និងកិច្ចការផ្ទះ (២-៣ នាទី)<br>. ការធ្វើចំណាត់ថ្នាក់រុក្ខជាតិម៉ូណូកូទីលេដូន។ | . សិស្សកត់ត្រា ហើយយកទៅស្រាវជ្រាវនៅផ្ទះ។ |

# សន្លឹកកិច្ចការ

## ប្រធានបទៈ ការសង្កេតទម្រង់ផ្កា (លក្ខណៈរបស់ផ្កា)

<u>សំណួរគន្លឹះ</u>

## តើផ្កាមានផ្នែកអ្វីខ្លះ?

<u>សម្មតិកម្ម</u>

| |
|---|
| |

<u>ដំណើរការសង្កេត</u>

-----

-----

-----

<u>លទ្ធផល</u>

-----

-----

-----

<u>សន្និដ្ឋាន</u>

-----

-----

-----

# ប្លង់ការខៀន

## ប្រធានបទ: ការសង្កេតទម្រង់ផ្កា (លក្ខណៈរបស់ផ្កា)

<u>សំណួរគន្លឹះ</u>

តើផ្កាមានផ្នែកអ្វីខ្លះ?

<u>សម្មតិកម្ម</u>




<u>ដំណើរការសង្កេត</u>

. បកផ្នែកខាងក្រៅរបស់ផ្កា ហើយបិតនៅលើក្រដាសជារង្វង់

. បកផ្នែកបន្ទាប់ ហើយបិតនៅផ្នែកក្នុងបន្ទាប់

. ធ្វើដូចនេះរហូតដល់អស់ផ្នែកទាំងអស់របស់ផ្កា

<u>លទ្ធផល</u>





ដ្យាក្រាមផ្កាម៉ូណូកូទីលេដូន



ដ្យាក្រាមផ្កាឌីកូទីលេដូន

រូបផ្កាផ្សេងទៀត

រូបផ្កាផ្សេងទៀត

<u>សន្និដ្ឋាន</u>

ផ្កាទាំងអស់សុទ្ធតែមានត្របក ស្រទាប កេសរឈ្មោល និងកេសរញី។ ផ្កាដែលមានត្របក និងស្រទាប់មានចំនួន៣ ឬពហុគុណ៣ ជាផ្ការបស់រុក្ខជាតិម៉ូណូកូទីលេដូន ហើយផ្កាដែលមានត្របក និងស្រទាប់មានចំនួន៤–៥ ឬពហុគុណ៤–៥ជាផ្ការបស់រុក្ខជាតិ ឌីកូទីលេដូន។

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី៥, គរុសិស្ស សាលាគរុកោសល្យ និងវិក្រឹតការខេត្ត

ជំពូកទី២: បរិស្ថាន មេរៀនទី៣ : ដី ទំព័រទី (៤២ –៤៤)

២. ប្រធានបទ: ប្រភេទដីខុសៗគ្នា(ដីស្រទាប់លើ និងស្រទាប់ក្រោម)

៣. រយៈពេល: ៥០នាទី

៤. វត្ថុបំណង

- <u>ចំណេះដឹង:</u> ពិពណ៌នាពីប្រភេទដីផ្សេងគ្នា មានល្បឿនជម្រាបទឹកខុសៗគ្នា បានល្អជាមួយសកម្មភាពក្នុងថ្នាក់រៀន។
- <u>ជំនាញ:</u> វិភាគយ៉ាងច្បាស់ពីប្រភេទដីផ្សេងៗគ្នាមានល្បឿនជម្រាបទឹកខុសៗគ្នា ដោយសារទំហំនៃគ្រាប់ដីខុសៗគ្នា របស់ប្រភេទដី តាមរយៈបទពិសោធការងារតាមក្រុម។
- <u>ឥរិយាបថ:</u> មានចំណាប់អារម្មណ៍កាន់តែខ្លាំងតាមរយៈសកម្មភាពនៅក្នុងថ្នាក់រៀនជាមួយសម្ភារសាមញ្ញ និងមានតម្លៃថោក។

៥. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យអនាម័យ សណ្តាប់ធ្នាប់ និងវត្តមាន | <u>ជំហានទី១</u><br>រដ្ឋបាលថ្នាក់ (២នាទី)<br>គ្រូតពិនិត្យសណ្តាប់ធ្នាប់ និងវត្តមានសិស្ស។ | . សិស្សឡើងរាយការណ៍ |
| . តើកត្តាអ្វីខ្លះ ដែលបង្កឱ្យមានការបំពុលខ្យល់ ដី និងទឹក?<br>. បច្ចុប្បន្ន តើរដូវនេះជារដូវអ្វី?<br>. តើអ្នកមានបទពិសោធនៅពេលភ្លៀងដែរ ឬទេ? បន្ទាប់ពីភ្លៀង តើទឹកនោះទៅណា?<br>. ពិតណាស់ថា អ្នកអាចឃើញកន្លែងខ្លះមានទឹកដក់នៅលើដី ហើយខ្លះគ្មានដក់ទឹកទេ។ | <u>ជំហានទី២</u><br>រំឭកមេរៀនចាស់ (៥នាទី)<br>. កត្តាបំពុលដី ខ្យល់ និងទឹក<br>. ទំនាក់ទំនង ភ្ជាប់មេរៀន ការជ្រាបរបស់ទឹកចូលក្នុងដី | . វារួមមានកត្តាមនុស្ស កត្តាធម្មជាតិ និងបច្ចេកវិទ្យា<br>. វាជារដូវវស្សា ឬភ្លៀង<br>. មាន៖ ទឹកហូរទៅតំបន់ទំនាប ដូចជា ស្ទឹង ទន្លេ...។<br>. ជួននៅលើដី ឬគ្មានទឹកនៅលើផ្ទៃដី។ |
| | <u>ជំហានទី៣</u><br>មេរៀនទី៣ មេរៀនថ្មី (៣៥នាទី) | |

| | មេរៀនទី៣៖ ដី<br>ដីស្រទាប់លើ និងស្រទាប់ក្រោម | |
|---|---|---|
| សំណួរគន្លឹះ៖ **តើប្រភេទដីផ្សេងគ្នា មានជម្រាបទឹកខុសគ្នាដូចម្ដេចដែរ? មូលហេតុអ្វី?** | | |
| <u>បង្កើតសម្មតិកម្ម</u><br>. ចូរយកសៀវភៅសរសេរមក ដើម្បីកត់ត្រា។<br>. ឱ្យសិស្សបង្កើតសម្មតិកម្មដោយខ្លួនឯង។ | <u>បង្កើតសម្មតិកម្ម</u> | . វាមានល្បឿនជម្រាបទឹកខុសៗគ្នា ដោយសារៈ<br>. ប្រភេទដីខុសគ្នា<br>. ដីខ្លះម៉ដ្ឋ ហើយដីខ្លះគ្រើម<br>. ដីខ្លះអាចស្រូបទឹកបានល្អ ហើយខ្លះមិនអាចស្រូបទឹកទេ<br>. ដីខ្លះឆ្អែតទឹក ហើយខ្លះមិនឆ្អែតទឹកទេ។ |
| <u>បង្កើតប្លង់ពិសោធ</u><br>. ពិភក្សាជាក្រុម (៥-៦នាក់ក្នុង១ក្រុម) ដើម្បីបង្កើតប្លង់ពិសោធ។<br>. ឱ្យតំណាងក្រុមនិមួយៗ ឡើងបកស្រាយបង្ហាញពីសម្ភារ និងដំណើរការពិសោធ។<br>. គ្រូបូកសរុប ប្លង់ពិសោធរួម និងពន្យល់ពីការរៀបចំសម្ភារសម្រាប់ពិសោធ។<br>. ស្នើឱ្យតំណាងក្រុមនិមួយៗមកយកសម្ភារ និងឧបករណ៍ | <u>បង្កើតប្លង់ពិសោធ</u><br>បង្ហាញគំនិតក្រុមនិមួយៗ<br><u>បូកសរុបប្លង់ពិសោធរួម</u><br>ចាក់ទឹក (ចំណុះស្មើគ្នា)<br> | . ពិភាក្សាតាមក្រុមនិមួយៗ ដើម្បីបង្កើតប្លង់ពិសោធ។<br>. តំណាងក្រុមនិមួយៗឡើងរាយការណ៍ទៅថ្នាក់ទាំងមូល ហើយពិភាក្សារួមគ្នា។<br>. ផ្លាស់ប្ដូរយោបល់គ្នាទៅលើប្លង់ពិសោធរួម។<br>. តំណាងក្រុមនិមួយៗទៅយកសម្ភារៈ និងឧបករណ៍។ |
| <u>ការធ្វើពិសោធ</u><br>. ដើរសម្របសម្រួល និងពិនិត្យតាមក្រុមនិមួយៗ ពីសម្ភារ និងដំណើរការការពិសោធ ហើយឱ្យកត់ត្រាលទ្ធផល។ | <u>ធ្វើពិសោធ</u><br>ដើរសម្របសម្រួលតាមក្រុម ពេលធ្វើពិសោធ និងកត់ត្រាលទ្ធផល។ | . ធ្វើដំណើរការពិសោធតាមក្រុមនិមួយៗ ហើយសង្កេត និងកត់ត្រាលទ្ធផលក្នុងសៀវភៅ។ |
| <u>វិភាគលទ្ធផល និងសន្និដ្ឋាន</u><br>. ឱ្យតំណាងក្រុមនិមួយៗឡើងបង្ហាញពីលទ្ធផល និងទាញសន្និដ្ឋានរបស់ក្រុមខ្លួន។ | <u>វិភាគលទ្ធផល</u> | . ក្រុមនិមួយៗវិភាគលទ្ធផល ហើយតំណាងក្រុមនិមួយៗ ឡើងបកស្រាយពីលទ្ធផល និងសន្និដ្ឋានរបស់ខ្លួនទៅក្រុមដទៃទៀត។ |

| | | |
|---|---|---|
| | <u>សេចក្តីសន្និដ្ឋានរួម</u><br>. ប្រភេទដីផ្សេងៗគ្នាមានល្បឿនជម្រាបទឹកខុសៗគ្នា ដោយសារទំហំនៃគ្រាប់ដីខុសៗគ្នាដូចជា៖<br>. ដីខ្សាច់មានគ្រាប់ដីដែលមានអង្កត់ផ្ចិតធំ (៣-៥ ម.ម) មានជម្រាបទឹកលឿន ហើយខ្សាច់ដែលគ្រាប់ដីមានអង្កត់ផ្ចិតតូច (០.៣-២ម.ម) មានជម្រាបទឹកមធ្យម។<br>. ដីមានគ្រាប់ដីដែលមានអង្កត់ផ្ចិតតូច ប្រហែល (០.០០១-០.២ម.ម) មានជម្រាបទឹកយឺត ប្រសិនបើប្រភេទដី មានគ្រាប់ដីកាន់តែតូច នោះវាមានជម្រាបទឹកកាន់តែយឺតទៀត។ | <u>សេចក្តីសន្និដ្ឋាន</u><br>. ប្រភេទដីផ្សេងគ្នាមានល្បឿនជម្រាបទឹកខុសៗគ្នា ដោយសារប្រភេទដីទាំងអស់ នោះមានទំហំគ្រាប់ដីខុសៗគ្នាគឺខ្លះធំ ខ្លះតូច ហើយខ្លះទៀតគឺម៉ដ្ឋ។ |
| . ក្នុងចំណោមកែវដាក់ដីទាំងអស់ខាងលើ តើកែវណាមួយមានជម្រាបទឹកលឿនជាងគេ និងយឺតជាងគេៗ មូលហេតុអ្វី?<br><br>. ហេតុអ្វីបានជា គេចោះប្រហោងជាច្រើន នៅបាតផើងផ្កាដែលធ្វើពីដីឥដ្ឋ? | <u>ជំហានទី៤</u><br>ពង្រឹងពុទ្ធិ(៧នាទី)<br>. រំឭកមេរៀនឡើងវិញ ទាក់ទងប្រភេទដី ដែលធ្វើពិសោធ។<br><br>. ផ្សារភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ។ | . កែវដែលដាក់គ្រួសធំមានជម្រាបទឹកលឿនជាងគេ ហើយកែវដែលដាក់ដីមានជម្រាបទឹកយឺតជាងគេ ដោយសារវាមានទំហំគ្រាប់ដីខុសគ្នា។<br>. ដោយសារផើងដែលធ្វើពីដីឥដ្ឋមានគ្រាប់ដីតូចៗ ហើយម៉ដ្ឋ ជាមូលហេតុដែលធ្វើឱ្យ ទឹកមិនងាយនឹងជ្រាបបាន ដូច្នេះហើយទើបបានជាគេត្រូវចោះប្រហោងវានៅបាតផើង។ |
| . ពេលបច្ចុប្បន្ននេះ នៅតាមលំនៅដ្ឋានខ្លះ យើងឃើញមានគេប្រើផើងចម្រោះទឹក។<br>. តើផើងចម្រោះទឹកនោះធ្វើឡើងពីប្រភេទដីអ្វី ហើយគេធ្វើយ៉ាងដូចម្តេច? | <u>ជំហានទី៥</u><br>កិច្ចការផ្ទះ និងបណ្តាំផ្ញើ (៣នាទី)<br><br>កិច្ចការស្រាវជ្រាវ | . ស្តាប់ និងកត់ត្រាកិច្ចការផ្ទះសម្រាប់ស្រាវជ្រាវ។ |

២. កិច្ចតែងការបង្រៀនគម្រូរបស់សិក្ខាកាម

២.១. រូបធាតុ

២.២. រូបធាតុ( ការចម្លង និងការរីកមាឌនៃអង្គធាតុរឹង )

២.៣. ប្រព័ន្ធព្រះអាទិត្យ

២.៤. វិញ្ញាណទាំងប្រាំរបស់ខ្ញុំ

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: គរុសិស្ស

២. មេរៀន: រូបធាតុ

៣. រយៈពេល: ៥០នាទី

៤. វត្ថុបំណង:

- ចំណេះដឹង:
  - គរុសិស្សប្រាប់បានពីប្រតិកម្មគីមីនៃរូបធាតុបានត្រឹមត្រូវតាមរយៈសំណួរបំផុស។
- ជំនាញ
  - គរុសិស្សកំណត់បានពីអត្តសញ្ញាណកម្មគីមីនៃរូបធាតុ (អុកស៊ីសែន) បានត្រឹមត្រូវតាមរយៈការធ្វើពិសោធតាមក្រុមក្នុងថ្នាក់។
- ឥរិយាបថ
  - គរុសិស្សមានចំណូលចិត្ត និងមានបម្រុងប្រយ័ត្នក្នុងការធ្វើពិសោធក្នុងជីវភាពរស់នៅ។

៥. សម្ភារៈបង្រៀន:

ដបទឹកសុទ្ធ ថ្លើមជ្រូក ធូប ឈើគូស ឬដែកកេះ ទឹកអុកស៊ីសែនណេ ការ៉ុត។

៦. ដំណើរការបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យថ្នាក់រៀនសិស្ស | <u>ជំហានទី១</u><br>គ្រូតពិនិត្យលំនឹងថ្នាក់<br>. អនាម័យ សណ្តាប់ធ្នាប់ វិន័យ<br>. អវត្តមានសិស្ស | . ប្រធានថ្នាក់រាយការណ៍ |
| . ដូចម្តេចដែលហៅថាបម្រែបម្រួលរូប? | <u>ជំហានទី២</u><br>រំលឹកមេរៀនចាស់<br>. បម្រែបម្រួលរូបជាបម្រែបម្រួលរូបរាងទ្រង់ទ្រាយ សណ្ឋាន ប៉ុន្តែរក្សាលក្ខណៈរបស់រូបធាតុនៅដដែល | . ឆ្លើយជាបុគ្គល |
| . រូបធាតុទាំងអស់មានបម្រែបម្រួល | <u>ទំនាក់ទំនងមេរៀនថ្មី</u><br>. រូបធាតុទាំងអស់មានបម្រែបម្រួល | . មិនដូចគ្នាទេ |

| | | |
|---|---|---|
| លក្ខណៈដូចគ្នាដែរ ឬទេ?<br>. ហែកក្រដាស A4 រួចសួរគរុសិស្ស តើនេះជាបម្រែបម្រួលអ្វី?<br>. យកឈើគូសដុតក្រដាស រួចសួរគរុសិស្ស តើនេះជាបម្រែបម្រួលអ្វី? | លក្ខណៈមិនដូចគ្នាទេ។<br>.ជាបម្រែបម្រួលរូប<br>. បម្រែបម្រួលគីមី | .ជាបម្រែបម្រួលរូប<br>. បម្រែបម្រួលគីមី |
| . ដូចម្ដេចហៅថាបម្រែបម្រួលគីមី?<br>. ឱ្យគរុសិស្សចាក់ទឹកអុកស៊ីសែនណោលើថ្លើមជ្រូក និងធ្វើការសង្កេត<br>. បិទសំណួរគន្លឹះ និងឱ្យគរុសិស្សអាន។ | ជំហានទី៣<br>មេរៀនទី១៦<br>បម្រែបម្រួលលក្ខណៈគីមីនៃរូបធាតុ ឬបាតុភូតគីមី ឬប្រតិកម្មគីមី<br>. គ្រប់កំណែប្រែរូបរាង លក្ខណៈនៃអង្គធាតុមួយក្លាយជាអង្គធាតុថ្មីផ្សេងទៀតហៅថាបម្រែបម្រួលគីមី | . ឆ្លើយជាបុគ្គល<br>. ចាក់ទឹកអុកស៊ីសែនណោ លើថ្លើមជ្រូក និងសង្កេត។<br>. អានសំណួរគន្លឹះ |
| សំណួរគន្លឹះ៖ ពេលប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណោ តើមានអ្វីកើតឡើង?<br>អង្គធាតុដែលកើតឡើងជាអ្វី? | | |
| . ចែកសន្លឹកកិច្ចការ<br>. ឱ្យគរុសិស្សទស្សន៍ទាយនៅពេលគេចាក់ទឹកអុកស៊ីសែនណោទៅលើថ្លើមជ្រូកតើគេសង្កេតឃើញដូចម្ដេច? អង្គធាតុដែលកើតឡើងជាអ្វី?<br>. ចែកសម្ភារពិសោធទៅឱ្យសិស្សតាមក្រុម។ | សម្មតិកម្ម<br>. កាលណាចាក់ទឹកអុកស៊ីសែនណោលើថ្លើមជ្រូកគឺមានឧស្ម័នកើតឡើង។ ឧស្ម័ននោះគឺឧស្ម័នអុកស៊ីសែន។ | . ទទួលសន្លឹកកិច្ចការពីគ្រូ<br>. ទស្សន៍ទាយ មានឧស្ម័នកើតឡើង។<br>សិស្សខ្លះថាៈ ជាឧស្ម័នអុកស៊ីសែនអ៊ីដ្រូសែន។<br>. តាមក្រុមទទួលសម្ភារពិសោធពីគ្រូ។ |

| | | |
|---|---|---|
| . ឱ្យគ្រុសិស្សបង្កើតប្លង់ពិសោធ និងបកស្រាយ។<br><br>. ណែនាំការពិសោធដល់សិស្សអំពីប្លង់ពិសោធ។<br><br>. ឱ្យគ្រុសិស្សធ្វើពិសោធតាមក្រុម<br>. សម្របសម្រួលការងារក្រុមដើម្បីកំណត់អត្តសញ្ញាណកម្មឧស្ម័នដែលកើតឡើង។ | <u>ពិសោធ</u><br><br><br><br> | . ចែកប្លង់ពិសោធក្នុងសន្លឹកកិច្ចការរួចឡើងបកស្រាយ។<br>. ប្លង់ពិសោធ:<br>. ដាក់ទឹកអុកស៊ីសែនណេទៅក្នុងដបទឹកសុទ្ធដែលមានថ្លើមជ្រូក។<br>. បិទគម្របដបទឹកសុទ្ធឱ្យជិត<br>. ស្តាប់ការណែនាំរបស់គ្រូ<br><br>. សិស្សធ្វើពិសោធតាមក្រុមនីមួយៗ |
| . ឱ្យគ្រុសិស្សបង្ហាញលទ្ធផលចំពោះការធ្វើពិសោធ។ | <u>លទ្ធផល</u><br>. ពេលគេចាក់ទឹកអុកស៊ីសែនណេលើថ្លើមជ្រូកគឺមានអុកស៊ីសែនកើនឡើងឧស្ម័នសម្គាល់ដោយរងើកភ្លើងធូបឆេះច្រាលឡើង។ | . សិស្សបង្ហាញលទ្ធផលពិសោធ: ពេលគេចាក់ទឹកអុកស៊ីសែនណេលើថ្លើមជ្រូកគឺមានឧស្ម័នកើតឡើង ឧស្ម័ននោះគឺឧស្ម័នអុកស៊ីសែនដែលសម្គាល់ដោយរងើកភ្លើងធូបឆេះច្រាលឡើង។ |
| . ឱ្យគ្រុសិស្សធ្វើការសន្និដ្ឋាន រួមចំពោះប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណេ។<br>. ឱ្យគ្រុសិស្សសរសេរសមីការតាងប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណេលើថ្លើមជ្រូក។<br>. គ្រូឱ្យសិស្សសរសេរអត្តសញ្ញាណកម្មអុកស៊ីសែន ដោយប្រើទឹកអុកស៊ីសែនណេ និងមើមការ៉ុត។ | <u>សន្និដ្ឋាន</u><br>ប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណេ គឺមានឧស្ម័នកើតឡើង។ ឧស្ម័នអុកស៊ីសែន ដែលសម្គាល់ដោយរងើកភ្លើងធូបឆេះច្រាល់ឡើង (ទ្រទ្រង់ចំហេះ)។<br><br><u>សមីការតាងប្រតិកម្ម</u><br>$H_2O_2 \xrightarrow{\text{ថ្លើមជ្រូក}} {}^{1}/_{2}O_2 + H_2O$ | . សិស្សធ្វើការសន្និដ្ឋាន:<br>ប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណេគឺមានឧស្ម័នកើតឡើង។ ឧស្ម័ននោះគឺ ឧស្ម័នអុកស៊ីសែនដែលសម្គាល់ដោយរងើកភ្លើងធូបឆេះច្រាលឡើង (ទ្រទ្រង់ចំហេះ)។<br>. សិស្សសរសេរសមីការ។ |

| | | |
|---|---|---|
| . ឱ្យសិស្សរកអត្តសញ្ញាណកម្មអុកស៊ីសែន ដោយប្រើទឹកអុកស៊ីសែនណេ និងមើមការ៉ុត។ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង)<br>. ការ៉ុតក៏អាចបំបែកទឹកអុកស៊ីសែនណេឱ្យទទួលបានអុកស៊ីសែន នឹងទឹកដែរ។ | . សិស្សអនុវត្តតាមក្រុមសង្កេតឃើញថាភ្លើងធូបឆេះច្រាលឡើង បញ្ជាក់ថាឧស្ម័នអុកស៊ីសែន ដែលទទួលបាន គឺជាឧស្ម័នបានជាឧស្ម័នអុកស៊ីសែន។ |
| . ឱ្យសិស្សកត់ត្រាមេរៀនសង្ខេប និងកិច្ចការផ្ទះ។ | <u>ជំហានទី៥</u><br>កិច្ចការផ្ទះ<br>. ចូរប្អូនធ្វើពិសោធដើម្បីកំណត់អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន ដោយប្រើទឹកអុកស៊ីសែនណេ ជាមួយបន្លែផ្សេងៗ ឬសាច់សត្វ។ | . សិស្សកត់ត្រាមេរៀម និងកិច្ចការផ្ទះ៕ |

# សន្លឹកកិច្ចការ

កាលណាចាក់ទឹកអុកស៊ីសែនណេទៅលើថ្លើមជ្រូកគេ និងឃើញមានអង្គធាតុថ្មីកើតឡើង។

| |
|---|
| ពេលប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនណេ តើមានអ្វីកើតឡើង?<br>អង្គធាតុដែលកើតឡើងជាអ្វី? |

សម្មតិកម្ម:

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

ប្លង់ពិសោធ:

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

លទ្ធផល:

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

សន្និដ្ឋាន:

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

<u>កិច្ចការផ្ទះ</u>

ចូរប្អូនធ្វើពិសោធដើម្បីកំណត់អត្តសញ្ញាណកម្មឧស្ម័នអុកស៊ីសែន ដោយប្រើទឹកអុកស៊ីសែនណេ ជាមួយបន្លែផ្សេងៗ ឬសាច់សត្វ។

លក្ខណៈវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិ |
|---|---|
| ទំនាក់ទំនងរវាងគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | . សិស្សអាចទាញសេចក្តីសន្និដ្ឋាន តាមរយៈសំណួរបំផុសរបស់គ្រូ<br>. ចុងក្រោយគ្រូទាញសេចក្តីសន្និដ្ឋានតាមរយៈសៀវភៅ ដែលពុំមែនចេញមកពីលទ្ធផលនៃការធ្វើពិសោធ។ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | . ដំណើរការបង្រៀនមានលក្ខណច្បាស់លាស់ អាចធ្វើសិស្សឆាប់យល់ និងងាយធ្វើពិសោធ។<br>. គ្រូគួរពន្យល់ប្រតិកម្មគីមីនៅក្នុងការបង្កើតសម្មតិកម្ម ពុំចាំបាច់រងចាំដល់ជំហានទី៤ទេ ព្រោះវាអាចធ្វើឱ្យសិស្សយល់ច្រឡំ។<br>. ការបង្រៀនល្អ ប៉ុន្តែក្នុងលំនាំបង្ហាញគ្រូគួរតែបង្ហាញដល់សិស្សគ្រប់ក្រុម និងបន្ថែមបរិមាណទឹកអុកស៊ីសែននេឱ្យច្រើនបន្តិច ដើម្បីឱ្យសិស្សឃើញច្បាស់។ |
| ឱកាសនៃការសិក្សា | . សិស្សបានរកឃើញបាតុភូត ដែលបានកើតឡើង ឧទាហរណ៍ ហ្គាស មានអ្វីកើតឡើងក្រោយពេលចាក់ទឹក $H_2O_2$ ទៅលើថ្លើមជ្រូក។<br>. សិស្សឆ្លល់លទ្ធផលពិសោធផ្សេងទៀត ឧ. ដូចគ្នា ឬខុសគ្នា ទៅនឹងការចាក់ទឹក $H_2O_2$ ទៅលើការ៉ុតម្តង។<br>. សិស្សសកម្ម និងមានការគិត សហការណ៍រីករាយក្នុងការធ្វើពិសោធ (ពិសោធពីរ បីដង)។ |

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: គរុសិស្ស

២. មេរៀន: រូបធាតុ (ការចម្លង និងការរីកមាឌនៃអង្គធាតុរឹង)

៣. រយៈពេល: ១ម៉ោង

៤. វត្ថុបំណង:

- គរុសិស្សប្រាប់បានពីការរីកមាឌនៃអង្គធាតុរឹងតាមរយៈសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ។
- គរុសិស្សកំណត់បានពីការរីកមាឌនៃអង្គធាតុរឹងត្រឹមត្រូវតាមរយៈការងារក្រុម។
- គរុសិស្សមានទម្លាប់ស្រាវជ្រាវ និងពិសោធន៍ងាយៗនៅក្នុងជីវភាពប្រចាំថ្ងៃ។

៥. សម្ភារ

- ក្រដាសរ៉ាម ស្កុត ហ្វឺត ចង្កៀងអាល់កុល ចង្កឹះលោហៈ គំនូសក្រិត សន្លឹកកិច្ចការ ក្រណាត់សើម ឆ្នាំង ចង្រ្កានហ្គាស ឈើគូស។

៦. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| . គ្រូតពិនិត្យថ្នាក់រៀនសិស្ស | <u>ជំហានទី១ (២នាទី)</u><br>គ្រូតពិនិត្យលំនិងថ្នាក់<br>. អនាម័យ សណ្តាប់ធ្នាប់ វិន័យ<br>. អវត្តមានសិស្ស | . ប្រធានថ្នាក់រាយការណ៍ |
| . តើអ្វីខ្លះជាអង្គធាតុរឹង?<br>. ក្នុងចំណោមលោហៈ ទាំងអស់ តើលោហៈណាខ្លះចម្លងកំដៅបានល្អជាងគេ?<br>. ក្រៅពីចម្លងកំដៅ តើអង្គធាតុរឹងទាំងនោះមានលក្ខណៈបម្រែបម្រួលអ្វីទៀត? | <u>ជំហានទី២ (៥នាទី)</u><br>រំលឹកមេរៀនចាស់<br>. លោហៈ ថ្ម ឈើ ដី ប្រាក់ ទង់ដែង មាស។<br><br>. មាឌ | . លោហៈ ថ្ម ឈើ ដី ប្រាក់ ទង់ដែង មាស។<br>ឆ្លើយតាមការយល់ឃើញ។ |

| | | |
|---|---|---|
| <u>សំណួរគន្លឹះ</u> | <u>ជំហានទី(៣០នាទី)</u><br>មេរៀនថ្មី<br>ការរីកមាឌនៃអង្គធាតុរឹង | |
| តើចង្កឹះលោហៈប្រែប្រួលដូចម្តេចពេលដុតកម្តៅ និងទុកឱ្យត្រជាក់? | | |
| . ឱ្យសិស្សបង្កើតសម្មតិកម្មដោយខ្លួនឯងតាមរយៈសន្លឹកកិច្ចការ។<br>. តើយើងអាចមើលការប្រែប្រួលទំហំចង្កឹះលោហៈបានដោយសារអ្វី?<br>. ចែកសន្លឹកកិច្ចការ<br>. ឲ្យសិស្សសរសេរលទ្ធផលលើសន្លឹកកិច្ចការ។<br>. ចែកសម្ភារៈ និងធ្វើពិសោធ<br>. ណែនាំពីរបៀបពិសោធ<br>. ដាក់ចង្កឹះលោហៈគងពីលើចង្កឹះទ្រនិច<br>. ដុតកំដៅលើចង្កឹះលោហៈ<br>. ពិនិត្យមើលបម្រែបម្រួលនៃទ្រនិច<br>. ឱ្យសិស្សធ្វើពិលោធ<br>. ពេលដុតកម្តៅ តើប្អូនសង្កេតឃើញទ្រនិចប្រែប្រួលដូចម្តេច?<br>. ហេតុអ្វីបានទ្រនិចប្រែប្រួល?<br>. សរសេរលទ្ធផល និងរាយការណ៍<br>. គ្រូសួរសំណួរបន្ត<br>. តើអង្គធាតុរឹង រីកមាឌតែបណ្តោយឬ?<br>. គ្រូធ្វើពិសោធទី២ ដើម្បីបញ្ជាក់<br>. យកឆ្នាំងដាក់ស៊កប្រឡោះដែកគោល។<br>. យកឆ្នាំងទៅដុតកម្តៅ ហើយសួរសិស្ស។ | . រីក រួម និងបណ្តោយ<br>. តាមការពិសោធ<br>. សន្លឹកកិច្ចការ<br>ធ្វើពិសោធទី១<br><br><br>. ទ្រនិចប្រែប្រួល<br>. ដែកលូតវែង<br>. រីកគ្រប់ទីកន្លែង<br>. ធ្វើពិសោធទី២ | . លូត និងរួញប្រវែង<br>. ការពិសោធន៍<br>. សន្លឹកកិច្ចការ<br>. បំពេញសន្លឹកកិច្ចការ<br>. អនុវត្តការពិសោធទី១ និងសង្កេត<br>. រាយការណ៍តាមក្រុម<br>. រាយការណ៍លទ្ធផលពិសោធ<br>. ឆ្លើយជាបុគ្គល<br>. សិស្សសង្កេត<br>. តាមក្រុម |
| . តើឆ្នាំងអាចស៊កចូលក្នុងប្រឡោះដែកគោលឬទេ?<br>. ចូរទាញសេចក្តីសន្និដ្ឋាន | . រីកមាឌ<br><u>សន្និដ្ឋាន</u><br>អង្គធាតុរឹងរីកមាឌកាលណាត្រូវ | . សេចក្តីសន្និដ្ឋានតាមក្រុម |

| | | |
|---|---|---|
| | កម្តៅ ហើយវារួមមាឌមកវិញកាលណាវាចុះត្រជាក់។ | |
| . ហេតុអ្វីបានជាគេសង់អាគារធំៗ និងផ្លូវរថភ្លើងគេទុកចន្លោះ?<br>. តើគេអនុវត្តគោលការណ៍រីកមាឌនៃអង្គធាតុរឹងអ្វីខ្លះនៅក្នុងជីវភាពប្រចាំថ្ងៃ?<br>. ឱ្យសិស្សចម្លងមេរៀនសង្ខេប | ជំហានទី៤ (៦នាទី)<br>. ប៉ានកង់រទេះគោ ស្ពាន<br>.មេរៀនង្ខេប | . សិស្សឆ្លើយតាមការយល់មេរៀន<br>. សិស្សឆ្លើយជាបុគ្គល<br>. សិស្សចម្លងមេរៀន |
| . ចូរប្អូនសង្កេតមើលសំណង់អាគារធំៗ និងផ្លូវរថភ្លើង។ | ជំហានទី (៥នាទី)<br>. បណ្តាំផ្ញើ | . ការអនុវត្តសង្កេត |

# សន្លឹកកិច្ចការ

<u>សំណួរគន្លឹះ</u>  តើចង្កឹះលោហៈ ប្រែប្រួលដូមម្ដេចពេលដុតកម្ដៅ និងទុកឱ្យត្រជាក់ ?

១. សម្មតិកម្ម

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

២. ចូររៀបចំសម្ភារពិសោធន៍

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

៣. ដំណើរការពិសោធន៍ (ចូរគូររូប)

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

ពេលដុតចង្កឹះលោហៈរយៈពេល ៥នាទី និងទុកឱ្យត្រជាក់យើង សង្កេតឃើញចង្កឹះប្រែប្រួលយ៉ាង

ដូចម្ដេច?

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

៤. តាមរយៈការពិសោធខាងលើនាំឱ្យយើង:

សន្និដ្ឋាន:

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

---------------------------------------------------------------------------------------------------------

លក្ខណៈវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិ |
|---|---|
| ទំនាក់ទំនងរវាងគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | . សិស្សអាចទាញសេចក្តីសន្និដ្ឋានដោយខ្លួន។<br>. វត្ថុបំណងល្អ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | . សិស្សរៀនតាមដំណើរការវិទ្យាសាស្ត្រ ប៉ុន្តែទំនាក់ទំនងនៃដំណើរការនីមួយៗពុំទាន់បានល្អនៅឡើយ ឧ. សេចក្តីផ្តើម ការបង្ហាញបាតុភូត ពិសោធ លទ្ធផល និងសេចក្តីសន្និដ្ឋាន។<br>. សកម្មភាពបង្រៀន និងរៀនសកម្ម ហើយសិស្សបានចូលរួមធ្វើពិសោធគ្រប់ៗគ្នា ប៉ុន្តែលំនាំនៃការប្រើប្រាស់ក្តារខៀនពុំទាន់សមស្រប ឧ. ការបិទក្រដាស។ |
| ឱកាសនៃការសិក្សា | . នៅត្រង់សេចក្តីផ្តើម និងការបង្ហាញបាតុភូត សិស្សហាក់បីដូចជា រិះរកបានច្រើន។ គ្រូគួរតែឱ្យសិស្សពិភាក្សាទៅលើគំនិតរបស់ពួកគេ ធ្វើដូចនេះ វាអាចជួយឱ្យថ្នាក់រៀនកាន់តែសកម្ម។<br>. សិស្សមានសកម្មភាពល្អ បានចូលរួមគ្រប់ៗគ្នា ប៉ុន្តែគ្រូគួរតែពិនិត្យ ឱ្យបានច្រើន ព្រោះក្រុមខ្លះទទួលបានលទ្ធផលយឺត។ |

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី៥

២. មេរៀន: ប្រព័ន្ធព្រះអាទិត្យ

៣. រយៈពេល: ១ម៉ោង

៤. វត្ថុបំណង:

- ចំណេះដឹង:
  - សិស្សប្រាប់ពីនិយមន័យប្រព័ន្ធព្រះអាទិត្យ និងភពផ្សេងៗនៃប្រព័ន្ធព្រះអាទិត្យបានត្រឹមត្រូវ ដោយផ្អែកលើសំណួរបំផុសរបស់គ្រូ។
- បំណិន:
  - កំណត់ពីភពផ្សេងៗនៃប្រព័ន្ធព្រះអាទិត្យ (លំដាប់ លំដោយ ចម្ងាយ) នៃភពទាំង៨បានត្រឹមត្រូវ ដោយផ្អែកលើការពិសោធន៍។
- ឥរិយាបថ:
  - ចូលចិត្តស្រាវជ្រាវ និងស្វែងយល់បន្ថែមតាមរយៈការមើលទូរទស្សន៍ ស្តាប់វិទ្យុ អានកាសែត ទស្សនាវដ្តី ដែលស្តីពីប្រព័ន្ធព្រះអាទិត្យ។

៥. សម្ភារ:

គ្រូ: ម៉ែត្រខ្សែ ភូគោល ផ្ទាំងសំណួរគន្លឹះ តារាងចម្ងាយពីព្រះអាទិត្យទៅរកភពផ្សេងៗ។

សិស្ស: ម៉ែត្រខ្សែ ភូគោល ប័ណ្ណឈ្មោះភពទាំង៨

៦. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| . ត្រួតពិនិត្យអនាម័យ<br>. ត្រួតពិនិត្យសណ្តាប់ធ្នាប់<br>. ត្រួតពិនិត្យអវត្តមាន | <u>ជំហានទី១ (២នាទី)</u><br>. អនាម័យ សណ្តាប់ធ្នាប់ វត្តមាន | . ប្រធានថ្នាក់រាយការណ៍ ពីចំនួនអវត្តមាន និងពេលសម្អាត។ |
| . តើនៅលើពិភពលោកយើងផ្ទៃទឹក និងផ្ទៃដីមួយណាធំជាង? | <u>ជំហានទី២ (៥នាទី)</u><br>រំលឹកមេរៀនចាស់<br>**ដី និងទឹក** | . ផ្ទៃទឹកធំជាងផ្ទៃដី |
| . សិស្សឡើងបកស្រាយបញ្ជាក់នៅលើភូគោល។ | នៅលើពិភពលោកយើងផ្ទៃទឹកធំជាងផ្ទៃដីព្រោះផ្ទៃទឹកមាន ២/៣ នៃ | . ឡើងបកស្រាយដោយសង្កេតមើលភូគោល។ |

<table>
<tr><td><br>. តើភាវរសទាំងអស់ដែលរស់នៅផែនដីទទួលកម្តៅមកពីណា?</td><td>ផ្ទៃដី។ ពណ៌ផ្ទៃមេឃមានចំនួនធំតំណាងឱ្យផ្ទៃទឹក ពណ៌បៃតង ឬពណ៌លឿងតូចតំណាងឱ្យផ្ទៃដី។<br><u>ទំនាក់ទំនងមេរៀន</u><br>. ភាវរសទាំងអស់ដែលរស់នៅលើផែនដី ទទួលកម្តៅពីព្រះអាទិត្យ។</td><td><br>. មកពីព្រះអាទិត្យ។</td></tr>
<tr><td>ថ្ងៃនេះយើងនាំគ្នាសិក្សាអំពីប្រព័ន្ធព្រះអាទិត្យ ។<br>. យកចំណងជើងមេរៀនបិទលើក្តារខៀន។<br>តើអ្វីទៅជាប្រព័ន្ធព្រះអាទិត្យ?<br>. បិទសំណួរគន្លឹះ</td><td><u>ជំហានទី៣ (២៦នាទី)</u><br><u>ប្រព័ន្ធព្រះអាទិត្យ</u><br>. ប្រព័ន្ធព្រះអាទិត្យគឺជាភពផ្សេងៗដែលវិលជុំវិញព្រះអាទិត្យ។</td><td>. ស្តាប់គ្រូដោយយកចិត្តទុកដាក់<br>. សង្កេត និងកត់ត្រា<br>. ភពច្រើនដែលនៅបន្តបន្ទាប់គ្នាភពដែលធ្វើចលនាជុំវិញព្រះអាទិត្យ<br>. សង្កេត និងអាន</td></tr>
<tr><td colspan="3">តើប្រព័ន្ធព្រះអាទិត្យមានភពអ្វីខ្លះ ហើយវាស្ថិតនៅតម្រៀបគ្នាយ៉ាងដូចម្តេច?</td></tr>
<tr><td>. ឱ្យសិស្សឆ្លើយនូវសំណួរគន្លឹះ<br>. គ្រូចាំបិទតាមការឆ្លើយរបស់សិស្សឱ្យសិស្សសង្កេតប័ណ្ណឈ្មោះភពហើយឡើងតម្រៀបតាមលំដាប់លំដោយ។<br>. សូមប្អូនៗពិនិត្យ មើលតើការតម្រៀបនេះត្រឹមត្រូវ ឬទេ?<br>. ហេតុអ្វីបានដឹងថាត្រឹមត្រូវ?<br>. យកតារាងចម្ងាយពីព្រះអាទិត្យទៅភពផ្សេងៗមកបិទលើក្តារខៀន ហើយពន្យល់ រួចឱ្យពួកគេឡើងអនុវត្តដោយប្រើខ្សែម៉ែត្រ នៅក្នុងថ្នាក់រៀន។</td><td>. ភពសៅរ៍ ភពសុក្រ ភពព្រហស្បត្តិ៍ ភពផែនដី ភពណិបទូន និងភពអង្គារ ភពអ៊ុយរ៉ានុស ភពពុធ។<br>. ភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ ភពព្រហស្បត្តិ ភពសៅរ៍ ភពអ៊ុយរ៉ានុស ភពណិបទូន។<br>. តាមការការតម្រៀបខាងលើគឺពិតជាត្រឹមត្រូវ តាមចំនួនចម្ងាយ ដែលបានសរសេរលើប័ណ្ណ។
<table>
<tr><th colspan="2">ចម្ងាយបង្រួមគិតជា m</th></tr>
<tr><td>ភពពុធ</td><td>0.60 m</td></tr>
<tr><td>ភពសុក្រ</td><td>1.10 m</td></tr>
<tr><td>ភពផែនដី</td><td>1.50 m</td></tr>
<tr><td>ភពអង្គារ</td><td>2.30 m</td></tr>
<tr><td>ភពព្រហស្បត្តិ៍</td><td>7.80 m</td></tr>
<tr><td>ភពសៅរ៍</td><td>14.30 m</td></tr>
<tr><td>ភពអ៊ុយរ៉ានុស</td><td>28.8 m</td></tr>
<tr><td>ភពណិបទូន</td><td>45.00 m</td></tr>
</table></td><td>. ឆ្លើយម្នាក់ម្តងនៅកន្លែង<br>. សិស្សសង្កេតប័ណ្ណភពនីមួយៗ និងតម្រៀបតាមការយល់ឃើញ។<br>. ពិនិត្យ សង្កេតរួចឆ្លើយត្រឹមត្រូវ និងមិនត្រឹមត្រូវ ទៅតាមចំនួនលេខលើប័ណ្ណភពនីមួយៗ។<br>. សង្កេតតាមចម្ងាយ និងស្តាប់នូវការពន្យល់របស់គ្រូ។<br>. ឡើងមកអនុវត្ត ដោយប្រើខ្សែម៉ែត្រវាស់តាមចម្ងាយភពនីមួយៗ ដែលមានក្នុងតារាង (ក្នុងថ្នាក់)</td></tr>
<tr><td>ពេលវាស់ក្នុងថ្នាក់មិនទាន់ហើយ ត្រូវបែងចែកសិស្សជាពីក្រុម ដើម្បីអនុវត្តនៅខាងក្រៅ ជួយពញ្ញាក់</td><td>ពេលក្រុមទី១កាន់ប័ណ្ណភព ក្រុមទី២ជាអ្នកសង្កេត។</td><td>. បន្តការវាស់អំពីភពនីមួយៗតាមក្រុម និងសង្កេត។</td></tr>
</table>

| | | |
|---|---|---|
| អារម្មណ៍សិស្សពេលពិសោធ និងសង្កេត។<br>. ក្រោយពីសង្កេត និងអនុវត្តរួចឱ្យពួកគេចូលក្នុងថ្នាក់រួចបង្ហាញការចាប់អារម្មណ៍នូវអ្វីដែលគេបានសង្កេតឃើញ។<br><br><br><br>. ឱ្យសិស្សផ្ទៀងផ្ទាត់លទ្ធផលដែលសង្កេតឃើញ ដើម្បីធ្វើការសន្និដ្ឋាន | . ប្រៀបធៀបចម្ងាយពីភព១ ទៅភព១ ដែលបានវាស់គិតជា ៣ ទៅចម្ងាយជាក់ស្តែង។<br>. យើងសង្កេតឃើញភពពុធ និងភពសុក្រនៅជិតព្រះអាទិត្យ ជាងគេ ហើយភពអ៊ុយរ៉ានុស និងភពណិបទូន នៅឆ្ងាយពីព្រះអាទិត្យ។<br><br><u>សន្និដ្ឋាន</u><br>ប្រព័ន្ធព្រះអាទិត្យមានភពដូចជាភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ ភពព្រហស្បត្តិ៍ ភពសៅរ៍ ភពអ៊ុយរ៉ានុស ភពណិបទូន។<br>វាស្ថិតនៅតម្រៀបគ្នាតាមលំដាប់លំដោយនៃចម្ងាយពីភពនីមួយៗ ដូចជាភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ នៅជិត ព្រះអាទិត្យ ហៅថាភពក្នុង ភពព្រហស្បត្តិ៍ ភពសៅរ៍ ភពអ៊ុយរានុស ភពណិបទូន នៅឆ្ងាយពីព្រះអាទិត្យ ហៅថាភពក្រៅ | . សង្កេត និងកត់ត្រាដោយចាប់អារម្មណ៍ ពីគម្លាតនៃភពនីមួយៗ។<br><br>. តំណាងក្រុមឡើងរាយការណ៍ពីអ្វីដែលពួកគេបានសង្កេតឃើញ ពេលអនុវត្តនៅខាងក្រៅថ្នាក់។<br><br><br>. ផ្ទៀងផ្ទាត់លទ្ធផលដើម្បីធ្វើសេចក្តីសន្និដ្ឋាន។ |
| <br><br>. តើភពណាខ្លះនៅជិតព្រះអាទិត្យជាងគេ និងភពណាខ្លះនៅឆ្ងាយព្រះអាទិត្យជាងគេ ចូរពន្យល់? | <u>ជំហានទី៤ (៥នាទី)</u><br>ពង្រឹងចំណេះដឹង<br>ភពដែលជាប្រព័ន្ធព្រះអាទិត្យមាន ៨គឺ:<br>ភពផែនដី ភពអង្គារ ភពព្រហស្បត្តិ៍ ភពសៅរ៍ ភពអ៊ុយរ៉ានុស ភពណិបទូន។ | <br><br>ភពដែលជាប្រព័ន្ធព្រះអាទិត្យមាន ៨គឺ ភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ ភពព្រហស្បត្តិ៍ ភពសៅរ៍ ភពអ៊ុយរ៉ានុស ភពណិបទូន។ |
| | . ភពនៅជិតព្រះអាទិត្យជាងគេគឺ ភពពុធ និងភពសុក្រ គឺមានកម្តៅខ្លាំងណាមិនអាចមានភាវរស់ រស់នៅបានទេ។<br>. ភពដែលនៅឆ្ងាយពីព្រះអាទិត្យ | . ភពនៅជិតព្រះអាទិត្យមានភពពុធ ភពសុក្រ ផែនដី និងភពអង្គារ។<br><br><br>. ភពនៅឆ្ងាយមាន ភពព្រហស្បត្តិ៍ |

| | | |
|---|---|---|
| | មានភពអ៊ុយរ៉ានុស និងភពណិបទូនគឺមិនអាចមានកម្ដៅ និងពន្លឺទេ ហើយក៏មិនអាចមានភាវៈរស់នៅបានដែរ។ | ភពសៅរ៍ ភពអ៊ុយរ៉ានុស ភពណិបទូន។ |
| . ពេលប្អូនត្រឡប់ទៅផ្ទះវិញ ចូរសរសេរលំដាប់លំដោយនៃភពទាំងអស់ឱ្យបានចំនួនប្រាំ។ | <u>ជំហានទី៥ (២នាទី)</u><br>កិច្ចការផ្ទះ | . កត់ត្រា ដើម្បីយកទៅអនុវត្តនៅផ្ទះ។ |

លក្ខណៈវិនិច្ឆ័យទៅលើការវាយតម្លៃ

| លក្ខណវិនិច្ឆ័យ | យោបល់ពីគ្រូឧទ្ទេសថ្នាក់ជាតិ |
|---|---|
| ទំនាក់ទំនងរវាងគោលបំណងមេរៀន និងលទ្ធផលនៃអ្នកសិក្សា | . សិស្សអាចទាញសេចក្តីសន្និដ្ឋានបានដោយខ្លួនឯង នៅចុងនៃមេរៀន។<br>. វត្ថុបំណងច្បាស់លាស់ |
| ដំណើរការនៃការរៀនមេរៀនវិទ្យាសាស្ត្រ | . សកម្មភាពទាំងអស់មានលក្ខណៈរស់រវើក និងគួរឱ្យចាប់អារម្មណ៍។ សិស្សនៅមានការពិបាកក្នុងការ បិទរូបប័ណ្ណភពទៅលើទីតាំងនិមួយៗ និងរបៀបបង្កើតចម្ងាយសមាមាត្រ ចេញពីចម្ងាយជាក់ស្តែង។<br>. បង្រៀន និងរៀនល្អដោយសិស្សបានគិតធ្វើសកម្មភាពក្រៅថ្នាក់ សំយោគដោយគិតពីចម្ងាយរវាងភព និងភព។ |
| ឱកាសនៃការសិក្សា | . សិស្សទាំងអស់រីករាយ និងសួរសំណួរបានច្រើន។ មេរៀននេះសមស្របតាមបែប IBL។ សំណួរភាគច្រើនគ្រូពិបាកក្នុងការផ្តល់ចម្លើយ។ ឧ. តើហេតុអ្វីបានជាភពស្ថិតនៅក្នុងប្រព័ន្ធព្រះអាទិត្យ? ហេតុអ្វីមានតែ៨ ? ហេតុអ្វីបានរូបភាពនៅលើ Poster តម្រៀបជា១ជួរ?<br>. សិស្ស និងអ្នកសង្កេតមានការយកចិត្តទុកដាក់ទៅលើការតម្រៀបនៃប្រព័ន្ធព្រះអាទិត្យ។ |

# កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀន: សិស្សថ្នាក់ទី២

២. មេរៀន: វិញ្ញាណប្រាំរបស់ខ្ញុំ

៣. រយ:ពេល: ៥០នាទី

៤. វត្ថុបំណង

- សិស្សប្រាប់វិញ្ញាណទាំង៥ បានត្រឹមត្រូវ តាមរយ:សំណួរបំផុសរបស់គ្រូ។
- សិស្សកំណត់តួនាទី វិញ្ញាណនិមួយៗ តាមរយ:ការពិភាក្សាក្រុមបានត្រឹមត្រូវ។
- បណ្តុះស្មារតីសិស្សថែរក្សា ការពារវិញ្ញាណទាំងប្រាំ។

៥. សម្ភារ:

ផ្ទាំងរូបភាព ប័ណ្ណពាក្យ ក្រដាស A4 និងហ្វឺត

៦. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| . ពិនិត្យអវត្តមាន និងអនាម័យ | <u>ជំហានទី១</u><br>ស្ថេរភាពថ្នាក់ | . សិស្សរាយការណ៍ |
| . ក្នុងការរស់នៅសព្វថ្ងៃរបស់មនុស្ស ក៏ដូចជាសត្វ តែងតែដឹងសភាពដែលនៅជុំវិញខ្លួន តែគ្រាន់តែមនុស្សអាចដឹងយល់បានច្រើនជាងសត្វ។<br>. ដូចនេះការដឹងនេះដោយសារអ្វី?<br>. បង្ហាញបាតុភូត<br>១. កែវទឹកស្ករ<br>២. ទឹកអំបិល<br>៣. ទឹកសុទ្ធ<br>តើការដឹងថាទឹកស្ករ ទឹកអំបិល ទឹកសុទ្ធ នេះដោយសារអ្វី? | <u>ជំហានទី២</u><br>I-សេចក្តីផ្តើម<br>ភាសាទំនាក់ទំនង<br>. វិញ្ញាណ<br><br> | . ឆ្លើយជាបុគ្គល<br>. តាមរយៈសមត្ថភាពស្រាប់ |

| | | |
|---|---|---|
| | ជំហានទី៣<br>មេរៀនទី១<br>វិញ្ញាណប្រាំរបស់ខ្ញុំ | |
| តើមនុស្សយើងមានសរីរាង្គវិញ្ញាណប៉ុន្មាន ហើយមាននាទីដូចម្ដេចខ្លះ? | | |
